# ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្តល់ទឹកបរិសុទ្ធតាមរយៈក្រុមហ៊ុន ស្រាបៀរអង្គរ ជូនខេត្តបន្ទាយមានជ័យ ចំនួន ៥000 កេស

ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានផ្តល់ទឹកបរិសុទ្ធអង្គរព្យូរ៉ូចំនួន៥ពាន់កេសតាមរយៈ ក្រុមហ៊ុនស្រាបៀរអង្គរ ចែកជូនដល់រដ្ឋបាលខេត្ត ដើម្បីប្រគល់ជូនប្រជាពលរដ្ឋ៨ស្រុក ដែលកំពុងខ្វះទឹកប្រើប្រាស់ និងបរិភោគ។

ឯកឧត្តម សួន បវរ អភិបាលខេត្តបន្ទាយមានជ័យ បានថ្លែងអំណរអគុណដល់ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ដែលបានចាត់ឲ្យក្រុមការងារចុះចែកទឹកជូនប្រជាពលរដ្ឋ ធ្វើឡើងតាមការផ្តួចផ្តើមពីសកម្មភាពចែកទឹកជូនប្រជាពលរដ្ឋ ទៅតាមអនុសាសន៍ របស់ **សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ក្នុងនោះក្រសួងឧស្សាហកម្ម និងសិប្បកម្ម សហការជាមួយក្រុមហ៊ុនស្រាបៀរអង្គរ បានបើកយុទ្ធនាការចុះចែកទឹកបរិសុទ្ធអង្គរព្យូរ៉ូជូនដល់ ប្រជាពលរដ្ឋរស់នៅក្នុងខេត្តបន្ទាយមានជ័យ ខណៈដែលប្រជាពលរដ្ឋនៅតាមមូលដ្ឋានទាំងនោះ កំពុងជួបនឹងបញ្ហាកង្វះទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។

ឯកឧត្តមអភិបាលខេត្តបន្តថា សម្រាប់យុទ្ធនាការ ផ្តល់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋ ក្នុងខេត្តមាន៨ស្រុក ដោយទឹកសុទ្ធមាន៥ពាន់កេស ដោយក្នុង១ស្រុក ទទួលបាន៦២៥កេស ដើម្បីយកទៅចែកជូនដល់ប្រជាពលរដ្ឋជាបន្ត។

ជាមួយគ្នានោះដែរ តំណាងក្រុមហ៊ុនស្រាបៀរអង្គរបានឲ្យដឹងថា ក្រុមហ៊ុនស្រារបៀរអង្គរ គឺជាក្រុមហ៊ុនឈានមុខគេក្នុងការចូលរួមចំណែក ក្នុងការងារសង្គម និងការចូលចំណែកជំរុញការអភិវឌ្ឍដល់សង្គមជាតិ ឲ្យកាន់តែមានភាពរីកចម្រើនឡើង ពីមួយថ្ងៃទៅមួយថ្ងៃជាពិសេស ការចូលរួមចែកទឹកស្អាតនៅពេលនេះ គឺជាការជួយទាន់ពេលវេលា ដល់បងប្អូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកក្នុងការប្រើប្រាស់ទឹកជាប្រចាំថ្ងៃ នៅក្នុងរដូវជួបភាពរាំងស្ងួតនេះ។


Angkor
FOUNDATION


Angkor
FOUNDATION


Angkor


Angkor puro